# ១.បរិស្ថានធម្មជាតរបស់ទន្លេមេគង្គ

## បរិស្ថានធម្មជាតនៅក្នុងអាងទន្លេមេគង្គ

ទន្លេមេគង្គគឺជាផ្លូវទឹកអន្តរជាតិមួយដែលមានប្រភពពីខ្ពង់រាបទីបេនិងហូរកាត់តាមដីសណ្តរទន្លេមេគង្គឆ្ពោះបន្តរហូតទៅដល់សមុទ្រចិនភាគខាងត្បូង។ទន្លេនេះសម្បូរទៅដោយជីវៈចម្រុះគ្រប់ប្រភេទដែលជាប់ចំណាត់ថ្នាក់ទីពីរបន្ទាប់ពីទន្លេអាមាហ្សូន(Peterson និង Middleton ២០១០)។ក្រៅពីត្រីដែលមាន៨៥០ប្រភេទទន្លេនេះក៏មានរុក្ខជាតិ២០,០០០ប្រភេទមានសត្វ៤៣០ប្រភេទមានដូចជាពពួកបក្សីចំនួន១,២០០ប្រភេទនិងពពួកល្មូននិងពពួកសត្វរស់នៅបានទាំងក្នុងទឹកនិងលើគោកចំនួន៨០០ផ្សេងទៀតផងដែរ (Thompson២០០៨)។អាងទន្លេនេះទាំងមូលមានផ្ទៃក្រឡា៧៩៥,០០០គ.ម²គឺស្មើពីរដងនៃផ្ទៃដីប្រទេសជប៉ុនដែលមានទំហំ៣៧៧,៩៤៧គ.ម²និង មានបណ្តោយប្រវែង៤,៩០៩គ.ម ( MRCឆ្នាំ២០០០: ៥)។




*រូបភាពទី១៖ទន្លេមេគង្គ*

ចម្ងាយរវាងប្រភពទន្លេនិងដីសណ្តរនៅក្នុងប្រទេសជប៉ុនមានចម្ងាយខ្លីដោយឡែកទន្លេមេគង្គហូរក្នុងរយៈចម្ងាយមួយដ៏ឆ្ងាយ។លក្ខណៈពិសេសមួយទៀតរបស់ទន្លេមេគង្គគឺនៅត្រង់រយៈកម្ពស់របស់វាធៀបជាមួយនីវ៉ូទឹកសមុទ្រដែលមិនមានភាពខុសគ្នាច្រើនរវាងប្រភពទន្លេនិងដីសណ្តរ។

ទន្លេមេគង្គហូរកាត់ប្រទេសចំនួន៦រួមមានប្រទេសចិន (ខេត្តQinghaiនិងខេត្តYunnan) ប្រទេសភូមា/មីយ៉ាន់ម៉ាប្រទេសឡាវប្រទេសថៃប្រទេសកម្ពុជានិងប្រទេសវៀតណាមហើយបន្ទាប់មកហូរចាក់ចូលទៅក្នុងសមុទ្រ។នៅក្នុងប្រទេសចិនភាគខាងលើក្បាលទន្លេដ៏ធំរបស់ក្នុងពិភពលោកចំនួនបីដែលរួមមានទន្លេYangtze ទន្លេមេគង្គនិងទន្លេSalween បានហូរប្រកៀកគ្នាដូចនេះហើយភូមិសាស្ត្រតំបន់នេះត្រូវបានគេហៅថាទន្លេស្របបី។បន្ទាប់មកទន្លេមេគង្គហូរចូលក្នុងប្រទេសឡាវតាមបណ្តោយព្រំដែនប្រទេសភូមា-ឡាវហើយក្រោយមកបន្ទាប់ពីហូរតាមបណ្តោយព្រំដែនថៃ-ឡាវទន្លេនេះបានហូរចូលក្នុងប្រទេសកម្ពុជាដែលជាកន្លែងតភ្ជាប់ជាមួយនឹងបឹងទន្លេសាបដែលជានិមិត្តរូបរបស់ប្រទេសកម្ពុជា។នៅចុងក្រោយទន្លេនេះហូរចូលក្នុងប្រទេសវៀតណាមដែលគេស្គាល់ថាជាទន្លេនាគប្រាំបួន។តំបន់ដីសណ្តរទន្លេមេគង្គនៅក្នុងប្រទេសវៀតណាមគឺជាតំបន់ផលិតស្រូវដ៏ធំបំផុតមួយរបស់ពិភពលោកហើយចាប់ពីទីនោះមកទន្លេមេគង្គហូរចាក់ចូលទៅក្នុងសមុទ្រចិនខាងត្បូង។

ទន្លេមេគង្គមានប្រភពមកពីការរលាយដុំទឹកកកនៅភ្នំHimalayas(ភ្នំហេមពាន្ត)ប៉ុន្តែទឹកដែលហូរពីផ្ទៃអាងផ្សេងៗនៅក្នុងប្រទេសចិនបានចូលរួមចំនែកដល់លំហូរទឹកទន្លេនេះចំនួន១៦% ប្រទេសភូមាចំនួន២%ប្រទេសឡាវចំនួន៣៥% ប្រទេសថៃចំនួន១៨%ប្រទេសកម្ពុជាចំនួន១៨% និងប្រទេសវៀតណាមចំនួន១១% (MRC ២០០៥) ។

| | ប្រទេសចិន | ប្រទេស ភូមា | ប្រទេសឡាវ | ប្រទេសថៃ | ប្រទេស កម្ពុជា | ប្រទេស វៀតណាម | ផ្ទៃអាងទឹក ទាំងមូល |
|---|---|---|---|---|---|---|---|
| ផ្ទៃអាងទឹក (គ.ម២) | ១៦៥,០០០ | ២៤,០០០ | ២០២,០០០ | ១៨៤,០០០ | ១៥៥,០០០ | ៦៥,០០០ | ៧៩៥,០០០ |
| ផ្ទៃអាងទឹក (គិតជា% នៃផ្ទៃរងទឹកភ្លៀង ទាំងមូល) | ២១ | ៣ | ២៥ | ២៣ | ២០ | ៨ | ១០០ |
| កម្រិតទឹក (គិតជា% នៃផ្ទៃរងទឹកភ្លៀង ទាំងមូល) | ១៦ | ២ | ៣៥ | ១៨ | ១៨ | ១១ | ១០០ |

*តារាង១៖ការប្រៀបធៀបផ្ទៃអាងទឹកទន្លេមេគង្គ រវាងប្រទេសទាំង៦ (MRC ឆ្នាំ២០០៥)*

អាងទន្លេមេគង្គទទួលរងឥទ្ធពលអាកាសធាតុពីខ្យល់មូសុងត្រូពិច។ចាប់ពីពាក់កណ្តាលខែឧសភាដល់ខែតុលាខ្យល់មូសុងនិរតីនាំមកនូវរដូវវស្សា។ចាប់ពីខែវិច្ឆិកាដល់ពាក់កណ្តាលខែមីនាតំបន់នេះ

ត្រូវរងឥទ្ធពលខ្យល់មូសុងឦសានដែលនាំមកនូវរដូវប្រាំង (MRC២០១០៖១៤)។រដូវប្រាំងនេះបន្តរហូតដល់ខែមេសាហើយបន្ទាប់មកនៅខែឧសភាភ្លៀងចាប់ផ្តើមធ្លាក់ដែលបង្ហាញពីការចាប់ផ្តើមនៃរដូវវស្សា។ក្រៅពីតំបន់នៅក្នុងប្រទេសចិនពេលវេលាដែលក្តៅបំផុតគឺនៅជុំវិញខែមេសា។




ដ្យាក្រាមទី២៖ សីតុណ្ហភាព និងកម្ពស់ទឹកភ្លៀងក្នុង ខេត្ត*អ៊ុប៊ុនរ៉ាតឆាថានី* (នាយកដ្ឋានឧត្តុនិយមខេត្ត*អ៊ុប៊ុនរ៉ាតឆាថានី* ប្រទេសថៃ ២០០៨)

កម្រិតទឹកភ្លៀងធ្លាក់ប្រចាំឆ្នាំនៅក្នុងខេត្តអ៊ុប៊ុនរ៉ាតឆាថានី(UbonRatchathani)ភាគឦសាននៃប្រទេសថៃមានកម្ពស់១,៥០០ម.ម។ចំនួននេះប្រហាក់ប្រហែលគ្នានឹងទីក្រុងតូក្យូដែរប៉ុន្តែក្នុងករណីមួយដូចមានបង្ហាញក្នុងដ្យាក្រាមទី២មានភ្លៀងធ្លាក់ខ្លាំងនៅចន្លោះខែឧសភានិងខែកញ្ញា។ចាប់ពីខែតុលារហូតដល់ដើមរដូវវស្សាក្នុងខែឧសភាពេញឆ្នាំបន្ទាប់មានភ្លៀងធ្លាក់តិចតួចបំផុត។ទន្លេមូន (Mun River)ដែលហូរកាត់តាមខេត្តអ៊ូប៊ុនរ៉ាតឆាថានីត្រូវទទួលរងឥទ្ធិពលពីលំនាំទឹកភ្លៀងនេះដូច្នេះកម្រិតទឹកចាប់ផ្តើមកើនឡើងនៅក្នុងខែឧសភានិងបន្តឡើងដល់កម្រិតខ្ពស់បំផុតនៅក្នុងខែតុលា។បន្ទាប់មកចាប់ពីខែវិច្ឆិកាដល់ខែមេសាកម្រិតទឹកចាប់ផ្តើមស្រកចុះបន្តិចម្តងៗវិញ។

មានតែទន្លេមេនៃអាងទន្លេមេគង្គទាំងមូលប៉ុណ្ណោះដែលទទួលបានទឹកពីការរលាយទឹកកកនៅភ្នំ Himalayas(ភ្នំហេមពាន្ត) ដូចនេះកម្រិតទឹករបស់ទន្លេមេនេះចាប់ផ្តើមកើនឡើងនៅក្នុងខែមេសា។ការប្រែប្រួលលក្ខណៈទាំងអស់នេះបង្កើតបានជាមូលដ្ឋាននៃបរិស្ថានធម្មជាតិដ៏វិសេសនិងប្រព័ន្ធជីវៈចម្រុះដ៏កម្រជាច្រើនប្រភេទផ្សេងៗគ្នានៅក្នុងអាងទន្លេមេគង្គ។

## <u>ឯកសារយោង</u>

Mekong River Commission (MRC). 2005. *Overview of the Hydrology of the Mekong Basin.*
http://www.mekonginfo.org/assets/midocs/0001968-inland-waters-overview-of-the-hydrology-of-the-mekong-basin.pdf

Mekong River Commission (MRC). 2010. *State of the Basin Report 2010.*
http://www.mrcmekong.org/assets/Publications/basin-reports/MRC-SOB-report-2010full-report.pdf

Peterson, B., and C. Middleton. 2010. *Feeding Southeast Asia: Mekong River Fisheries and Regional Food Security.* Berkeley, California: International Rivers (IR).
http://www.internationalrivers.org/files/attached-files/intrivers_mekongfoodsecurity_jan10.pdf

Thompson, C. 2008. *First Contact in the Grater Mekong*.World Wildlife Fund (WWF) Greater Mekong Programme.
http://awsassets.panda.org/downloads/first_contact_final_report.pdf

Tone River Management Office of the Ministry of Land, Infrastructure, Transport, and Tourism, Kanto Regional Development Bureau.
*What are the Unique Characteristics of Japan's Rivers?* (in Japanese).
http://www.ktr.mlit.go.jp/tonedamu/tonedamu00082.html (Last accessed on September 30, 2012)

# ឃិគូឈិយូកា

# ២. ប្រភេទត្រីនៅក្នុងអាងទន្លេមេគង្គ

ប្រភពដ៏សំខាន់នៃប្រូតេអ៊ីនសម្រាប់ប្រជាជនដែលរស់នៅក្នុងតំបន់ជនបទនៃអាងទន្លេមេគង្គក្រោម (ប្រទេសទាំងបួននៃទន្លេមេគង្គក្រោមដោយមិនរាប់បញ្ចូលប្រទេសចិននិងមីយ៉ាន់ម៉ា) គឺត្រីនិងប្រភេទមច្ឆាទឹកសាបផ្សេងៗទៀត។ដោយលើកលែងតំបន់ដីសណ្តរទន្លេមេគង្គប្រទេសវៀតណាមដែលនៅជាប់សមុទ្រនោះអត្រានៃការទទួលទានត្រីទឹកសាបមានកម្រិតខ្ពស់បំផុតនៅស្ទើរគ្រប់តំបន់ទាំងអស់នៃអាងនេះ។យើងសូមផ្តល់នូវទិដ្ឋភាពរួមមួយនៅទីនេះពីការប្រើប្រាស់ត្រីទន្លេមេគង្គដោយប្រជាជននៅក្នុងតំបន់ដោយដកស្រង់ចេញពីអត្ថបទស្តីពីការវាយតម្លៃទិន្នន័យដើមនៃធនធានជលផល(២០១០) របស់ឯកសារស្តីពី"**ការវាយតំលៃបរិស្ថានទន្លេមេគង្គជាយុទ្ធសាស្រ្តរបស់គណៈកម្មការទន្លេមេគង្គ**"។

## ១. ប្រភេទត្រីនៅក្នុងអាងទន្លេមេគង្គ

អត្ថបទស្តីពីការប៉ាន់ប្រមាណទិន្នន័យដើមនៃធនធានជលផល(២០១០) បានវាយតំលៃពីប្រភេទត្រីក្នុងទន្លេមេគង្គដោយយកទិន្នន័យចុះបញ្ជីក្នុងប្រព័ន្ធទិន្នន័យFishBaseដែលកត់ត្រាទុកពីប្រភេទត្រីដែលរស់នៅក្នុងទន្លេចំនួន២០៨និងបឹងចំនួន៣២ទូទាំងពិភពលោក។យោងទៅតាមទិន្នន័យដែលបានចុះបញ្ជីឆ្នាំ២០០៩ត្រីចំនួន៧៨១ប្រភេទដែលគេរកឃើញនៅក្នុងទន្លេមេគង្គជាប់ចំណាត់ថ្នាក់ទីពីរបន្ទាប់ពីទន្លេអាមាហ្សូន(Amazon) ដែលមានត្រីរហូតដល់១,២៧១ប្រភេទហើយតួលេខនេះក៏បញ្ជាក់ផងដែរថាទន្លេមេគង្គជាទន្លេទីពីរនៅលើពិភពលោកដែលមានប្រភេទត្រីចម្រុះ។យោងតាមរបាយការណ៍មួយដែលចេញដោយអង្គការមូលនិធិសត្វព្រៃពិភពលោក(WWF) បានឲ្យដឹងថាអាងទន្លេមេគង្គគឺជាបណ្តុំនៃជីវៈចម្រុះដែលប្រភេទត្រីថ្មីៗជាង២៧៩ប្រភេទត្រូវបានរកឃើញនៅក្នុងទសវត្សចុងក្រោយ។កាលពីមុនគេបានវាយតម្លៃថាមានត្រីប្រមាណ១,២០០ប្រភេទប៉ុណ្ណោះនៅក្នុងទន្លេមេគង្គប៉ុន្តែបច្ចុប្បន្នវិញគេគិតថាត្រីទឹកសាបមានប្រហែល៨៥០ប្រភេទហើយអាចមានរហូតដល់១,១០០ប្រភេទផ្សេងទៀតមករស់នៅក្នុងទន្លេប្រសិនបើត្រីសមុទ្រដែលបំលាស់ទីមករស់នៅបណ្តោះអាសន្នក្នុងតំបន់ដីសណ្តរទន្លេមេគង្គត្រូវបានរាប់បញ្ចូល។លើសពីនេះទៀតត្រីចំនួន១៩៧ប្រភេទត្រូវបានចុះបញ្ជីនៅក្នុងប្រព័ន្ធទិន្នន័យFishBaseថាជាត្រីរស់នៅក្នុងបឹងទន្លេសាបដែលចំនុចនេះបង្ហាញថាបឹងនេះគឺជាបឹងទីបួននៅលើពិភពលោកដែលសម្បូរត្រីគ្រប់ប្រភេទ(បឹងប៊ីវ៉ាBiwa)របស់ប្រទេសជប៉ុនជាប់ចំណាត់ថ្នាក់ទីប្រាំមួយដែលមានសត្វចំនួន៦៩ប្រភេទ)។

ចំនួនប្រភេទត្រីនៅ២០ទីតាំងនៅក្នុងអាងទន្លេមេគង្គ (ដោយរាប់បញ្ចូលទាំងអាងដៃទន្លេទាំងឡាយ) ត្រូវបានបង្ហាញក្នុងតារាងខាងក្រោម៖

**តារាងបង្ហាញពីប្រភេទសត្វនៅក្នុង២០ទីតាំងនៃអាងទន្លេមេគង្គ**

| ទីកន្លែង | ប្រភេទ | អំបូរ | ចំនួនរកឃើញ |
|---|---|---|---|
| ប្រភពទឹកទន្លេមេគង្គនៅប្រទេសចិន | ២៤ | ៣ | ៤ |
| ខ្សែទឹកទន្លេមេគង្គភាគខាងលើក្នុងប្រទេសចិន | ៣៤ | ៤ | ៤ |
| ខ្សែទឹកទន្លេមេគង្គភាគកណ្តាលក្នុងប្រទេសចិន | ៤៨ | ៨ | ៧ |
| ខ្សែទឹកទន្លេមេគង្គភាគខាងក្រោមក្នុងប្រទេសចិន | ១២២ | ២១ | ១៥ |
| ប្រទេសឡាវភាគខាងជើង ទន្លេមេគង្គ | ១៤០ | ៣០ | ២៦ |
| ទន្លេណាមអ៊ូ(Nam Ou) | ៧២ | ១៥ | ២៩ |
| ទន្លេណាមង៉ុំ(Nam Ngum) | ១៥៦ | ២៧ | ៤៣ |
| ទន្លេណាមម៉ាង(Nam Mang) | ៥៧ | ១៩ | ១៧ |
| ទន្លេណាមខាឌីញ(Nam Kadinh) | ៩៩ | ២១ | ៣៨ |
| ទន្លេសុងក្រាម(Songkhram) | ២១៦ | ៤០ | ៣៩ |
| ទន្លេហ្សេបាងហ្វៃ (Xe Bang Fai) | ១៥៧ | ៣១ | ៥១ |
| ទន្លេហ្សេបាងហាំង (Xe Bang Hiang) | ១៦០ | ៣៣ | ៤៧ |

| | | | |
|---|---|---|---|
| ទន្លេមូន/ជី (Mun/Chi) | ២៧០ | ៣៨ | ៤៩ |
| ទឹកធ្លាក់ល្បាក់ខោនខាងក្រោមនៃទន្លេមេគង្គ (Khone Fall) | ១៦៨ | ៣៤ | ២៥ |
| ទន្លេមេគង្គខេត្តស្ទឹងត្រែង–ក្រចេះ | ២០៤ | ៣៧ | ៣៣ |
| ទន្លេសេកុង (Sekong) | ២១៤ | ៣៣ | ៦៣ |
| ទន្លេសេសាន្ត (Sesan) | ១៣៣ | ២៦ | ២៤ |
| ទន្លេស្រែពក (Srepok) | ២០៤ | ៣២ | ៣៨ |
| ទន្លេសាប (Tonle Sap) | ២៨៤ | ៤៥ | ៣១ |
| ដីសណ្តរមេគង្គ(Mekong Delta) | ៤៨៦ | ៧៣ | ២៨ |

គណៈកម្មការទន្លេមេគង្គ៖សម្រង់អត្ថបទស្តីពីការវាយតំលៃទិន្ន័យដើមនៃធនធានជលផលឆ្នាំ២០១០ ទំព័រ១១

យោងតាមតារាងខាងលើដោយមិនរាប់បញ្ចូលតំបន់ដីសណ្តរទន្លេមេគង្គដែលជាកន្លែងត្រីទឹកប្រៃរស់នៅមានត្រីជាច្រើនប្រភេទកំពុងរស់នៅតាមដៃទន្លេរបស់ទន្លេមេគង្គដូចជាអាងទន្លេសុងក្រាមនិងអាងទន្លេមូន/ជីក្នុងប្រទេសថៃនិងនៅតាមដងទន្លេមេក្នុងខេត្តស្ទឹងត្រែងខេត្តក្រចេះនិងអាងទន្លេសេកុងនិងស្រែពកក្នុងប្រទេសកម្ពុជា៕

**<u>ឯកសារយោង</u>**

International Center for Environmental Management (ICEM). 2010.
*Mekong River Commission (MRC) Strategic Environmental Assessment (SEA) for Hydropower on the Mekong Mainstream: Fisheries Baseline Assessment Working Paper*.Vientiane, Lao PDR: MRC.
http://www.mrcmekong.org/about-the-mrc/programmes/initiative-on-sustainable-hydropower/strategic-environmental-assessment-ofmainstream-dams/

ឃិគូឈិយូកា

# ៣. អាងទឹកទន្លេមេគង្គ-ជាពិភពជលផលទឹកសាបដ៏ធំជាងគេបំផុតក្នុងលោក

## ១. ការទទួលទានត្រីទឹកសាប

បើយោងទៅតាមរបាយការណ៍ស្តីពីធនធានជលផល(ឆ្នាំ២០១០) សំដៅទៅខាងលើការចាប់ត្រីទឹកសាប នៅក្នុងប្រទេសទាំងបួននៃអាងទន្លេមេគង្គក្រោមដែលបានបង្ហាញនៅក្នុងស្ថិតិរបស់អង្គការការស្បៀង និងកសិកម្មដែលហៅជាភាសាអង់គ្លេសថា(FAO)នៃអង្គការសហប្រជាជាតិបានបញ្ជាក់ថាចំនួនត្រីចាប់បានសរុប៧៥០០០០តោនក្នុងមួយឆ្នាំ ប៉ុន្តែបើយោងតាមការស្ទង់មតិនៅមូលដ្ឋានវិញអាចធ្វើការប៉ាន់ប្រមាណថាផលត្រីប្រមាណ២.១លានតោនដែលត្រូវបានចាប់បានក្នុងមួយឆ្នាំៗដែលស្មើនឹង១៨% នៃទិន្នផលត្រីទឹកសាបដែលនេសាទបាននៅទូទាំងពិភពលោក។ យោងតាមការគណនានៃស្ថិតិរបស់អង្គការ ស្បៀងនិងកសិកម្ម(FAO)បានបង្ហាញថាការបរិភោគត្រីទឹកសាបប្រចាំឆ្នាំសម្រាប់មនុស្សម្នាក់នៅតាមអាងទន្លេមេគង្គក្រោមគឺស្មើរនឹង១៣,៨គីឡូក្រាមក្នុងមួយឆ្នាំ ខណៈដែលអត្រានៃការបរិភោគត្រីទឹកសាបក្នុងសកលលោកជាមធ្យមមានត្រឹមតែ ២.៣គីឡូក្រាមប៉ុណ្ណោះ។ ការបរិភោគត្រីទឹកសាបប្រចាំឆ្នាំនៅក្នុងប្រទេសកម្ពុជាវិញស្មើរនឹង១៩,៤គីឡូក្រាមគឺខ្ពស់ជាងគេបំផុតនៅក្នុងពិភពលោក។ មានសេចក្តីសង្ខេបរបាយការណ៍ស្ទង់មតិចំនួន២០ផ្សេងទៀតបានបង្ហាញថា ការបរិភោគត្រីទឹកសាបប្រចាំឆ្នាំជាមធ្យមសម្រាប់មនុស្សម្នាក់អាចច្រើនរហូតដល់ទៅ៣២,៣គីឡូក្រាមសំរាប់ប្រទេសកម្ពុជា ២៤,៥គីឡូក្រាមសម្រាប់ប្រទេសឡាវ ២៤,៩គីឡូក្រាមសម្រាប់ប្រទេសថៃនិង ៣៤,៥គីឡូក្រាមសម្រាប់ប្រទេសវៀតណាម។បើយោងទៅតាមទិន្នន័យរបស់អង្គការ ស្បៀងនិងកសិកម្ម (FAO)សម្រាប់ឆ្នាំ ២០០០ដល់ឆ្នាំ២០០៣ ស្តីពីសត្វដែលមានជាតិប្រូតេអ៊ីនត្រូវគេបានបរិភោគក្នុងមួយថ្ងៃៗឃើញថាបានមកពីសត្វត្រីមានរហូតដល់ទៅ៤៩,៨% នៅក្នុងប្រទេសកម្ពុជា ៣៨,៣១% នៅក្នុងប្រទេសឡាវ ១៦,១៩% នៅក្នុងប្រទេសថៃនិង ១២,៨៧ក្នុងប្រទេសវៀតណាមដែលអាចបញ្ជាក់ឲ្យឃើញថាមានអត្រាខ្ពស់ខ្លាំង បើធ្វើការប្រៀបធៀបជាមួយអត្រាមធ្យមភាគជាសកលរហូតដល់ទៅ៥,៧៨%។ ប្រទេសកម្ពុជានិងប្រទេសឡាវ គឺមានការលេចធ្លោជាពិសេស នៅក្នុងប្រៀបធៀបនេះ។

## ២. ទិន្នផលត្រីទន្លេមេគង្គ

មានទិន្នន័យថ្មីពេលបច្ចុប្បន្នបានបង្ហាញថា ការនេសាទត្រីពីអាងមេគង្គត្រូវបានគេប៉ាន់ស្មានថាមានគុណតម្លៃសម្រាប់សេដ្ឋកិច្ចប្រចាំឆ្នាំពី២,១ (USD2.1) ពាន់លានដុល្លារ ទៅ៣,៨ (USD 3.8)ពាន់លានដុល្លារនិងពី៤,២(USD4.2)ពាន់លានដុល្លារ ទៅ៧,៦(USD7.6)ពាន់លានដុល្លារនៅឯតម្លៃទំនិញលក់រាយ (អាយស៊ីអឹម (ICEM) ឆ្នាំ២០១០) ។





នៅក្នុងតំបន់ជុំវិញនៃទឹកធ្លាក់ល្បាក់ខោន(Khone)នៅភាគខាងត្បូងនៃប្រទេសឡាវដែលជាតំបន់នេសាទសំខាន់នៃទន្លេមេគង្គដែលបានផ្គត់ផ្គង់ដល់ការការរស់នៅទៅដល់ប្រជាជនចំនួន៦៥,000គ្រួសារ។ ជាមធ្យមក្នុងមួយគ្រួសារគិតថាអាចចាប់ត្រីបានចំនួន៣៥៥គីឡូក្រាមនិងបរិភោគត្រីជាមធ្យមចំនួន២៨៩គីឡូក្រាម។

ផលត្រីសរុបដែលនេសាទបានពីតំបន់ក្បែរជួរទឹកល្បាក់ខោន(Khone)ប្រមាណជា៤,០០០តោន ដែលមានតម្លៃពី៤៥០,០០០(USD450,000) ទៅ១(USD1)លានដុល្លា (បារាណ(Baran), ចាន់ថឿន (Jantunen) និងចុងឆ្នាំ 2008) ។

មានប្រភពព័ត៌មានផ្សេងៗគ្នាបានធ្វើកា ារប៉ាន់ប្រមាណថាការផលិតត្រីទឹកសាបរួមទាំងការធ្វើកសិកម្មត្រីនៅក្នុងប្រទេសកម្ពុជាសម្រាប់គណនាចំនួនរវាង១១,៧% និង ១៦% ឬរវាង ៨និង ១២%នៃផលិតផលក្នុងស្រុកសរុប។ ខណៈពេលដែលតួលេខទាំងនេះគឺជាការប៉ាន់ប្រមាណទាំងអស់ហើយវាពិបាកណាស់ដើម្បីទទួលបានស្ថិតិត្រឹមត្រូវសម្រាប់អ្នកនេសាទខ្នាតតូចសារៈសំខាន់នៃផលផលទន្លេមេគង្គដែលអាចត្រូវបានយល់ពីទិន្នន័យប្រហាក់ប្រហែលទាំងនេះដោយ (អាយអ៊ីស៊ីអឹម(ICEM )ឆ្នាំ២០១០) ។

## ៣.ត្រទ្រទ្រង់ជីវិតប្រចាំថ្ងៃ និងវប្បធម៌

នាពេលបច្ចុប្បន្ននេះដោយសារតែការអភិវឌ្ឍបង្កើតឲ្យមានគ្រឿងបរិក្ខារដូចជាទូរទឹកកក និងបណ្តាញដឹកជញ្ជូនដ៏សំបូរបែបនោះ ត្រីដែលចាប់បានពីអាងទន្លេមេគង្គ គឺកំពុងត្រូវបានចែកចាយនៅទូទាំងព្រំដែនអន្តរជាតិ។ជាការពិតណាស់ ត្រីមានសារៈសំខាន់សំរាប់ដោះដូរហើយមុនពេលប្រព័ន្ធចែកចាយត្រូវបានបង្កើតឡើង ការដោះដូត្រីត្រូវការទីកន្លែងដើម្បីធ្វើការប្តូរទំនិញគ្នាទៅវិញទៅមក។

រហូតមកដល់ប្រមាណជា៥0ឆ្នាំមុន ការដោះដូរត្រីនិងស្រូវបានធ្វើឡើងយ៉ាងទូលំទូលាយនៅក្នុងតំបន់ដែលរួមបញ្ចូលទាំងតំបន់ភាគខាងត្បូងនៃប្រទេសឡាវនិងភាគឦសាននៃប្រទេសថៃ។ នៅក្នុងសម័យនោះ នៅពេលដែលការចិញ្ចឹមជីវិតមនុស្សជាសកលបានចំណាយពេលវេលារបស់ពួកគេដើម្បីប្រមូលផ្តុំឬស្វែងរកអាហារនៅក្នុងគោលបំណងដើម្បីធានាការផ្គត់ផ្គង់ចំណីអាហារ។

នៅក្នុងភូមិ មុខរបរដែលសំខាន់ជាងគេគឺការធ្វើស្រែចំការ ដែលធ្វើឲ្យពួកគេមានការពិបាកក្នុងការរកពេលដើម្បីស្វែងរកអាហារបន្ថែម (ដើម្បីបរិភោគជាមួយបាយ) ក្នុងកំឡុងពេលបង្ករបង្កើនផល និងប្រមូលផលស្រូវជាដើម។ នៅពេលវេលាដូចគ្នានេះដែរ ច្រាំងទន្លេនៅតាមភូមិដែលជាទីកន្លែងសម្បូរ,ត្រី ងាយ

ស្រួលក្នុងការនេសាទត្រីនៅទីនោះ ហើយបានបំលែងទៅជាត្រីដែលចាប់បាននោះ ជាចំណីអាហារដូចជាផ្អកឬត្រីឆ្អើរ(ឬអាហារក្រៀម)ដែលអ្នកភូមិអាចធ្វើការដោះដូរជាមួយទំនិញផ្សេងៗដែលពួកគេត្រូវការ។ ចំណីអាហារត្រូវបាធ្វើការចែកចាញដោយធ្វើការដោះដូរគ្នាទៅវិញទៅមក។

ការដោះដូរទាំងនេះមិនត្រឹមតែត្រូវបានអនុវត្តន៍តាមទិដ្ឋភាពជាក់ស្តែងប៉ុណ្ណោះទេតែក៏មានសារៈសំខាន់សំរាប់សង្គមនិងវប្បធម៌ផងដែរ។

ភាគឦសានប្រទេសថៃ ស្ត្រីជនជាតិថៃម្នាក់នៅក្នុងវ័យ៧០ឆ្នាំរបស់នាងមានដែលមានការទាក់ទងទៅនឹងយុវ័យរបស់នាងដែលនាងបានធ្វើអាហារដែលក្រៀម ដូចជាត្រីងៀត ប្រហុក និងផ្អក។ ពួកគេបានដឹកយកទៅលក់ដោយរទេះគោនិងជាញឹកញាប់កំណត់ពេលចេញរួមព្រមគ្នាជាមួយនឹងមិត្តភក្តិដោយគ្មានការកំណត់ឬសម្រេចពីទិសដៅណាមួយទេ។ បន្ទាប់មកនាងបាននឹងចរចាជាមួយមនុស្សដែលនាងបានជួបនៅតាមបណ្តោយផ្លូវដើម្បីធ្វើការដោះដូរជាមួយត្រីដែលនាងយកមកជាមួយនឹងអង្ករនិងផលិតផលកសិកម្មដទៃទៀត។ មិនមានអត្រាថេរទេសម្រាប់ការដោះដូរអង្ករនិងត្រី ដូច្នេះនៅពេលដែលនាងបានលើសនាងនឹងផ្តល់ឱ្យបន្ថែមទៅដល់មនុស្សផ្សេងទៀត តែប្រសិនបើនាងមានរយៈពេលខ្លីក្នុងការផ្គត់ផ្គង់ នោះនាងនឹងចរចាជាមួយមនុស្សផ្សេងទៀតដើម្បីឲ្យទទួលបានស្រូវច្រើនច្រើន។ ចំនុចនេះ បានពន្យល់អំពីសារៈសំខាន់នៅក្នុងការចរចារគឺត្រូវធ្វើឱ្យគេមានចិត្តទូលាយ។

នៅពេលនេះ ទាំងអង្ករ និងត្រីគឺមិនត្រូវបានគេចែកចាយតាមរយៈទីផ្សារទេដូច្នេះហើយក៏មិនអាចដោះដូរជាសាច់ប្រាក់ដែ។វាអាចត្រូវបានសន្មត់ថាប្រជាជនមានអារម្មណ៍ថាគ្មានចំណុចណាមួយដែលត្រូវកំណត់អត្រាដោះដូរថេរជាលេខនោះទេ។ លើសពីនេះទៀត ទាំងត្រី ឬអង្ករគឺមិនអាចត្រូវបានធ្វើបម្រុងទុកសម្រាប់រយៈពេលយូជាជាងការខ្ជះខ្ជាយដោយបោះចោល គឺត្រូវព្យាយាមប្តូរយកប្រាក់ឲ្យបានច្រើនតាមដែលអាចធ្វើបាន ហើយជាមេរៀនក្នុងសង្គមបានបង្ហាញថា ការចេះផ្តល់ឱ្យរបស់ទាំងនេះជាចិត្តសប្បុរសទៅអ្នកផ្សេងទៀតនេះ គឺដើម្បីបង្កើនកេរ្តិ៍ឈ្មោះរបស់គេនិងការពង្រឹងទំនាក់ទំនងរវាងបុគ្គល និងបុគ្គល ដែលវាជាវិធីដ៏ល្អក្នុងការផ្តល់ប្រឆាំងនឹងកាលៈទេសៈណាមួយដែលកើតឡើងដោយមិនបានរំពឹងទុក។ យើងក៏បានរៀនពី បទសម្ភាសផងដែរថាការកំណត់ទៅភូមិដែលមិនស្គាល់ៈ ដើម្បីធ្វើការដោះដូរ និងបង្កើតទំនាក់ទំនងមិត្តភក្តិថ្មីៗ គឺជាអ្វីដែលប្រជាជននៅទីនោះរីករាយនឹងធ្វើ។ មនុស្សដែលបានក្លាយជាមិត្តភក្តិតាមរយៈការដោះដូរ ត្រូវបានគេហៅថា សៀវ (siaow) (ហាក់ដូចមានន័យថា ជាមិត្តជិតស្និទ្ធ) ដែលតែងតែទៅសួរសុខទុក្ខគ្នាទៅវិញទៅមក។ បន្ទាប់ ពិធីអាពាហ៍ពិពាហ៍អាចនឹងកើតមានឡើងរវាងពីរគ្រួសារទាំងពីរ ដោយហេតុនេះមានន័យថា ការពង្រឹងទំនាក់ទំនងតាមរយៈការដោះដូរទៅជាមិត្តភក្តិ អាចបង្កើនទំនាក់ទំនងទៅសាច់ញាតិបាន។

ឥឡូវនេះត្រីអាចត្រូវបានគេលក់បានយ៉ាងងាយស្រួលសម្រាប់ការដោះដូយកសាច់ប្រាក់, ចាស់ទុំជាច្រើនសោកស្តាយនៅពេលដែលត្រីដែលអាចត្រូវបានចែករំលែកតាមរយៈការដោះដូរនោះប៉ុន្តែសូម្បីតែពេលបច្ចុប្បន្ននេះ ចំពោះភាគខាងត្បូងប្រទេសឡាវនៅពេលដែលចាប់ត្រីបាន ត្រីទាំងនេះត្រូវបានគេចែកឱ្យមិត្តភក្តិនិងសាច់ញាតិ។ នៅក្នុងភូមិមួយនៃភាគឦសាននៃប្រទេសថៃនៅពេលដែលផលត្រីដែលនេសាទ

បានមានបរិមាណតិច ហើយការចំណាយលើប្រេងសាំងដើម្បីយកត្រីទៅទីផ្សារមិនសមាមាត្រគ្នា ឬមិនបានចំនេញ ,ត្រីទាំងនេះត្រូវបានលក់នៅក្នុងភូមិក្នុងតំលៃទាប។ ត្រអាងទន្លេមេគង្គនាពេលបច្ចុប្បន្ននេះ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការពង្រឹងទំនាក់ទំនងសង្គមនិងគាំទ្រដល់សន្តិសុខស្បៀងរបស់ប្រជាជនដែលមានឱកាសតិចតួចដើម្បីទទួលបានប្រាក់ចំណូលជាសាច់ប្រាក់។

**<u>ឯកសារយោង :</u>**


Baran, Eric, JantunenTeemu, and ChiewKieok Chong, 2008.*Value of Inland Fisheries in the Mekong River Basin, Tropical River Fisheries Valuation: Background Paper to Global Synthesis* 227-290.

International Center for Environmental Management (ICEM). 2010. *Mekong River Commission (MRC) Strategic Environmental Assessment (SEA) for Hydropower on the Mekong Mainstream: Fisheries Baseline Assessment Working Paper.* Vientiane, Lao PDR: MRC.

http://www.mrcmekong.org/about-the-mrc/programmes/initiative-on-sustainable-hydropower/strategic-environmental-assessment-ofmainstream-dams/


ឃិគូឈិយូកា

# ៤. ការចិញ្ចឹមជីវិតរបស់ប្រជាជនតាមដងទន្លេមេគង្គ

## ១. ប្រជាជននិងទន្លេ

ចំនួនប្រជាជនតាមអាងទឹកទន្លេមេគង្គលើសពី៦០លាននាក់។ ចំនួនប្រជាជននៃតំបន់អាងទន្លេមេគង្គនៅក្នុងប្រទេសនិមួយៗមាន៥,២លាននាក់នៅក្នុងប្រទេសឡាវ២៣,១លាននាក់នៅក្នុងប្រទេសថៃ,១៣លាននាក់នៅក្នុងប្រទេសកម្ពុជានិង ១៨,៧លាននាក់នៅក្នុងប្រទេសវៀតណាម។ ប្រមាណជា ៨៥% គឺជាសហគមន៍កសិកម្ម (គណៈកម្មាធិការទន្លេមេគង្គ(MRC)ឆ្នាំ ២០១០ទំព័រ៣១-៣២) ។ កសិកម្មការនេសាទការប្រមូលនៃជីវិតក្នុងទឹក និងបន្លែគឺជាសកម្មភាពសេដ្ឋកិច្ចដ៏សំខាន់របស់ប្រជាជនក្នុងអាងទន្លេ ហើយប្រហែលជា៦២,៦%នៃចំនួនប្រជាជនដែលធ្វើការនៅក្នុងតំបន់បង្កើតការរស់នៅរបស់ពួកគេជាមូលដ្ឋានបានពីការងារដែលទាក់ទងនឹងធនធានទឹក (គណៈកម្មាធិការទន្លេមេគង្គ(MRC)ឆ្នាំ ២០១០ទំព័រ៤៨) ។

ទន្លេមេគង្គមិនត្រឹមតែផ្គត់ផ្គង់ទឹកប្រើប្រាស់សំរាប់តំបន់ទីក្រុងប៉ុនណ្ណោះទេរ,វាក៏ជាប្រភពទឹកសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃនៅក្នុងសហគមន៍កសិកម្មក្នុងរដូវប្រាំងផងដែរ។ នៅក្នុងភូមិនានាតាមបណ្តោយដងទន្លេមេគង្គដែលស្ទើរតែរាល់ទឹកផឹកទឹកសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃនិងទឹកសម្រាប់វិស័យកសិកម្មទាំងអស់ គឺពឹងអាស្រ័យលើទន្លេ។ ទន្លេនេះគឺមានសារៈសំខាន់ណាស់ ហើយក៏ជាកន្លែងសម្រាប់កុមារលេងផងដែរ។

នៅពេលដែលកម្រិតទឹកថយចុះនៅក្នុងរដូវប្រាំងតំបន់ក្លាយទៅជាស្ងួតខ្លាំងហើយមាត់ទន្លេក្លាយទៅជាទីកន្លែងដ៏សំខាន់មួយសម្រាប់ការធ្វើកសិកម្ម។ លើសពីនេះទៀតសោតដ៏ ជាប្រភពដ៏សំខាន់នៃប្រូតេអ៊ីនសម្រាប់សហគមន៍កសិកម្មគឺត្រីទឹកសាបដែលត្រូវបានគេចាប់នេសាទទាំងនៅតាមដងទន្លេនិងដៃទន្លេផ្សេងៗទៀត ក៏ដូចជាដីសើមនិងផ្លូវទឹកដែលតភ្ជាប់ទៅឱ្យពួកគេ។ នាពេលបច្ចុប្បន្ននេះមានត្រីប្រមាណជា ៨៥០ប្រភេទដែលបានកំណត់ថា មាននៅក្នុងអាងទន្លេមេគង្គហើយភាគច្រើនអាចត្រូវបានបរិភោគ។ សណ្ឋានជីវិតក្នុងទឹករួមទាំងត្រីនិងកង្កែបគឺជាប្រភពប្រូតេអ៊ីនចំបងសំរាប់ប្រជាជន ព្រមទាំងជាប្រភពដ៏សំខាន់នៃការរកប្រាក់ចំណូលផងដែរ។ ប្រសិនបើរាប់បញ្ចូល ខាងអាជីវកម្មនិងពលកម្មតាមរដូវកាល គឺប្រជាជន៤០លាននាក់នៅក្នុងតំបន់នេះត្រូវបានចូលរួមនៅក្នុងឧស្សាហកម្មនេសាទនៃប្រព័ន្ធទឹកទន្លេមេគង្គ។ប្រហែល៤០%នៃចំនួនប្រជាជនរបស់ប្រទេសកម្ពុជាគឺអាស្រ័យនៅលើទឹកបឹងទន្លេសាប និងទីវាលដែលទឹកជំនន់នៅជុំវិញ (គណៈកម្មាធិការទន្លេមេគង្គ(MRC )ឆ្នាំ ២០១០ទំព័រ៤៩) ។



ទន្លេក៏ជាផ្លូវដឹកជញ្ជូនដ៏សំខាន់ដែរ។ វាមិនមែនជារឿងចម្លែកសម្រាប់មនុស្សពីភូមិជាច្រើននៅតាមដងទន្លេទាំងសងខាងនេះធ្វើអោយមានការទំនាក់

ទំនងឆ្ងាយពីគ្នានោះទេ។ កន្លងមកនៅក្នុងខេត្តអាបូណរាឆាថានធី(UbonRatchathani)នៃប្រទេសថៃ មនុស្សដែលរស់នៅខាងថៃអាចធ្វើការដាំដុះដំណាំវិលជុំ(swidden)របស់ពួកគេនៅលើភ្នំនៃប្រទេសឡាវបាន។ សម្រាប់ពួកគេទន្លេនេះមិនមែនជាព្រំដែនជាតិយ៉ាងខ្លាំងខ្លានោះទេ វាគ្រាន់តែជាអ្វីដែលត្រូវឆ្លងកាត់យ៉ាងសមញ្ញទៅវិញ។

## ២. ជំនឿខាងវិញ្ញាណនិងទន្លេ

ទន្លេមេគង្គនិងទន្លេដទៃទៀតនៅក្នុងតំបន់ គឺមានមានសារៈសំខាន់ខាងវិញ្ញាណពិសេសសម្រាប់មនុស្សទាំងនោះផងដែរ។ នៅក្នុងប្រទេសថៃ,ឡាវនិងកម្ពុជា មានប្រាសាទពុទ្ធសាសនានិងវត្តអារាមនានាដែលជាទីកន្លែងនៃជំនឿរបស់មនុស្សត្រូវបានកសាងឡើងជាញឹកញាប់នៅតាមបណ្តោយមាត់ទន្លេ។ ក្នុងអំឡុងពេលនៃការសិក្សាតាមមូលដ្ឋាននេះ មានឱកាសជាញឹកញាប់ឮរឿងព្រេងនិទានជាច្រើន។ ឧទហរណ៍នៅភាគខាងត្បូងប្រទេសឡាវវាត្រូវបានគេដំណាលថាមានវាំងសត្វនាគនៅខាងក្រោមនៃទន្លេមេគង្គ។ វាត្រូវបានគេជឿថាមានព្រលឹងដ៏រឹងមាំរស់នៅក្នុងទន្លេនិងនៅកន្លែងពិសេសផ្សេងទៀតដូច្នេះវាអាចនឹងមានគ្រោះថ្នាក់ដល់ដំណើរការទូកនេសាទឬការឆ្លងកាត់ទីតាំងដែលមិនបានធ្វើការឧទ្ទិសបួងសួង។ តាមបណ្តោយទន្លេដមណូយ(DOM Noi)នៅក្នុងប្រទេសថៃដែលជាដៃនៃ ទន្លេមូន (Mun) មួយ វាគឺជាដៃនៃទន្លេមេគង្គ មនុស្សតែងតែសុំការអនុញ្ញាតពីព្រលឹង ឬអារក្ស មុនពេលនេសាទ។ គួរបញ្ជាក់ផងដែរនៅក្នុងប្រទេសថៃនិងប្រទេសឡាវត្រូវបាននិយាយយ៉ាងទូលំទូលាយថាទន្លេគឺជាតំណែលនៃការប្រយុទ្ធ របស់នាគ។

ព្រះវិញ្ញាណបាននិយាយថា មានវិញ្ញាណចិតនៅក្នុងត្រី។ទោះប្បីជាទំហំដ៏ធំសម្បើមក្តី រឺតូចក្តីត្រូវបានគេស្គាល់អំពីជីវិតត្រីឆ្លាំងយក្សរបស់មេគង្គត្រីទឹកសាបដ៏ធំបំផុតរបស់ពិភពលោកជាមួយនឹងភាពពេញវ័យមានទំងន់រហូតដល់ ៣០០គឡូក្រាមឯណោះ។ វាត្រូវបានគេមានជំនឿដោយសហគមន៍នេសាទថៃទោះជាយ៉ាងណាក៏ដោយ ជីវិតត្រីឆ្លាំងយក្សរស់នៅដោយសារសមាទានសីលព្រះពុទ្ធនិងភាពពិសិដ្ឋរបស់វាគឺដោយសារតែ មានស្លែនិងបន្លែផ្សេងទៀតត្រូវបានគេធ្លាប់រកឃើញនៅក្នុងពោះរបស់វាតែប៉ុណ្ណោះ។ នៅក្នុងប៉ែកតព្ស៊ីសាន្ត ខេត្តអាណបូ រាចាថានី(UbonRatchathani)របស់ប្រទេសថៃវាត្រូវបានគេជឿថានៅពេលដែលត្រីនេះត្រូវបានគេចាប់នៅក្នុងសំណាញ់របស់នរណាម្នាក់គឺជារឿងមិនសូវល្អនោះទេ។ ឥឡូវត្រីទាំងនេះអាចត្រូវបានគេលក់សម្រាប់ថវិការយ៉ាងច្រើន ប៉ុន្តែដោយសារតែមានការភ័យខ្លាចនៃការបាត់បង់ជីវិតរបស់មនុស្សម្នាក់ៗចំពោះការប្រព្រឹត្តអំពើបាបនៃការសំលាប់ត្រី អ្នកនេសាទបានអនុវត្តបន្តជាផ្លូវការសេវារំឭកព្រះពុទ្ធសាសនា បន្ទាប់ពីការលក់ត្រីឆ្លាំងយក្ស។...



ទន្លេនេះក៏ជាទីកន្លែងនៃពិធីបុណ្យផ្សេងៗ។

ជារៀងរាល់ឆ្នាំមានការប្រណាំងទូកនៅលើទន្លេមេគង្គនិងដៃទន្លេរបស់វានៅជុំវិញពេលរដូវវស្សាបញ្ចប់នោះ។ ដូចគ្នានេះផងដែរនៅក្នុងអំឡុងពេលចូលខែឆ្នាំថ្មីរបស់ប្រជាពលរដ្ឋថៃនិងឡាវនៅខែមេសា។

មនុស្សដែលប្រារព្ធពិធីនៅតាមបណ្តោយដងច្រាំងទន្លេបានកសាងប៉មដីខ្សាច់នៅលើចេតិយព្រះពុទ្ធសាសនា។ ពិធីនេះបានធ្វើឡើងនៅក្នុងទីតាំងបេតិកភណ្ឌពិភពលោកនៃហ្លួងព្រះបាងតដែលមានឈ្មោះល្បីផងដែរប៉ុន្តែទំនៀមទម្លាប់ស្រដៀងគ្នានេះត្រូវបានអង្កេតផងដែរនៅក្នុងតំបន់ដែលបានស្គាល់តិចជាងដូចជាទន្លេមុន(Mun)ជាដៃទន្លេមេគង្គមួយនៅក្នុងភាគឦសាននៃប្រទេសថៃនិង ទន្លេសេកុងនៃប្រទេសកម្ពុជា។

## ៣.ការប្រើប្រាស់ទន្លេថ្មី

នៅលើខ្ពង់រាបបូឡាវេន(Bolaven)នៃប្រទេសឡាវមានការប្រើប្រាស់កើនឡើងនៃការបង្កើតវារីអគ្គិសនីខ្នាតតូចដោយប្រើម៉ាស៊ីនភ្លើងអគ្គីសនីតូចរបស់ប្រទេសចិន។ ម៉ាស៊ីនទាំងនេះត្រូវបានលក់នៅលើទីផ្សារក្នុងស្រុកនិងអ្នកភូមិខ្លួនឯងផ្ទាល់អាចដំឡើងឧបករណ៍ដ៏សាមញ្ញនិងងាយស្រួលនេះប្រសិនបើមានគ្រួសារមួយចំនួនធ្វើការវិនិយោគរួមគ្នា ចំណាយប្រាក់ប្រហែល២០០-៣០០ដុល្លារអាមេរិក។ ការធ្លាក់ចុះនៃ កំពស់ទឹក២ម៉ែត្រ គឺគ្រប់គ្រាន់ដើម្បីបង្កើតអគ្គិសនីបាន។ ដូច្នេះទោះបីជាគ្មានការផ្តល់ជំនួយក៏ដោយ អ្នកភូមិអាចប្រើប្រាស់ធនធានផ្ទាល់ខ្លួនរបស់ពួកគេដើម្បីទទួលបាននិងរក្សាថាមពលអគ្គីសនី។ ក្នុងភូមិដែលគ្មានអគ្គីសនីនៅក្នុងប្រទេសឡាវមានប្រជាជនខ្លះបានបង្កើតអាជីវកម្មសាកអាគុយដែលជាការផ្តល់កំណើតដល់អាជីវកម្មខ្នាតតូច។

**<u>ឯកសារយោង:</u>**

Mekong River Commission (MRC). 2010. *State of the Basin Report 2010.*

http://www.mrcmekong.org/assets/Publications/basin-reports/MRC-SOB-report-2010full-report.pdf

ឃិគូឈិយូកា

# ៥. ភាពចំរុះផ្សេងគ្នាវប្បធម៌ចំរុះគ្នា ភាសាផ្សេងៗនៅក្នុងតំបន់ទន្លេមេគង្គ



វិហាមូននៅខេត្តរ៉ាត់ឆាបួរីភាគខាងលិចប្រទេសថៃ (ខែកញ្ញាឆ្នាំ២០១២)

ភាសាសរុបទាំងអស់មាន៣៩៨ភាសាត្រូវបាននិយាយក្នុងប្រទេសមេគង្គទាំង៥ (ភូមាឡាវថៃកម្ពុជាវៀតណាម)[1]។ចំនួននេះស្មើនឹង៥.៨% នៃចំនួនភាសាសរុប៦,៩០៩ដែលបានចុះបញ្ជីរាយឈ្មោះភាសាពិភពលោកEthnologue។ម្យ៉ាងទៀតចំនួនអ្នកនិយាយភាសាក្នុងប្រទេសទាំង៥នេះគឺមាន៣.២%នៃពិភពលោក ដូច្នេះមានន័យថា៣.២%នៃអ្នកនិយាយភាសា៥.៨%នៃភាសាទាំងអស់ក្នុងពិភពលោក។វាធ្លាក់ចុះទាបនៃតំបន់ប៉ាស៊ីហ្វិក (0.១% នៃអ្នកនិយាយភាសា១៨.១%នៃភាសា) ហើយតំបន់ទ្វីបអាមេរិកខាងជើងនិងខាងត្បូង (0.៨%នៃអ្នកនិយាយភាសា១៤.៤%នៃភាសា) ប៉ុន្តែបើប្រៀបធៀបជាមួយអឺរ៉ុប (២៦.១%នៃអ្នកនិយាយភាសា៣.៤%នៃភាសា) ឬអាស៊ីទាំងមូល (៦០.៨%នៃអ្នកនិយាយភាសា៣៣.៦%ភាសា) វាអាចនិយាយបានថាមានភាសាផ្សេងៗចំរុះបែបយ៉ាងក្នុងចំណោមចំនួនប្រជាជនក្នុងតំបន់ទន្លេមេគង្គ[2]។

| ប្រទេស | # អ្នកនិយាយភាសា | # ភាសា | ភាសាមានអ្នកនិយាយតិចជាង ១០,០០០នាក់ | ឧទាហរណ៍ |
|---|---|---|---|---|
| កម្ពុជា | ១៣,៥១១,៩៧០ | ២៣ | ១២ | ព្រៅ,សំរែ,ស្អូច |
| ឡាវ | ៥,៣៤៩,៨៩៤ | ៨៤ | ៤៧ | អាហឺ,អារ៉ែម,ឆុត |
| ភូមា | ៤៧,៣១៩,៨០០ | ១១១ | ៣៥ | អានុ,តាវឆិន,ហ្វូន |
| ថៃ | ៥១,៦៦៨,៩៩៧ | ៧៤ | ២៨ | ប៊ីសុ,ឆុង,ផ្លង់ |
| វៀតណាម | ៧៥,៦៥០,០៩៩ | ១០៦ | ៤២ | អារ៉ែម,ឆុត,អន |
| សរុប (៥ប្រទេស) | ១៩៣,៥០០,៧៦០ | ៣៩៨ | ១៦៤ | |
| ពិភពលោកសរុប | ៥,៩៥៩,៥១១,៧១៧ | ៦,៩០៩ | ៣,៥២៤ | |
| ភាគរយ | ៣.២% | ៥.៨% | | |

[1]យោងតាមចំនួនបានផ្តល់ក្នុងបញ្ជីរាយឈ្មោះភាសាក្នុងពិភពលោកEthnologue (Lewis 2009)

[2]ក្នុងទ្វីបអាហ្វ្រិក១២.២%នៃអ្នកនិយាយភាសា ប្រើប្រាស់៣០.៥%នៃភាសាក្នុងពិភពលោក

## ភាសានៅក្នុងប្រទេសទាំង៥ក្នុងតំបន់ទន្លេមេគង្គ

ក្នុងចំណោម៣៩៨ភាសាចំនួនភាសា១៦៤ (៤១.២%) មានអ្នកនិយាយតិចជាង១០ពាន់នាក់[3]។ខណៈការរស់រាននៃភាសាមិនមែនត្រូវបានសំរេចដោយចំនួនអ្នកនិយាយទាំងស្រុងទេ(Nettleនិង Romaine២០០០) បន្ទាប់ពីធ្វើការគណនាចេញពីការពិនិត្យប្រៀបធៀប(Crystal២០០០) ប៉ាន់ប្រមាណថា៥០%នៃភាសានឹងបាត់បង់ក្នុងពេល១០០ឆ្នាំខាងមុខនិងភាគរយនៃភាសាក្នុងពិភពលោកដែលមានអ្នកនិយាយតិចជាង១០ពាន់នាក់គឺមានចំនួនពិតប្រាកដ៥១.០% (៣,៥២៤ភាសា)។ដូច្នេះវាមានជំរើសខ្ពស់ដែលថាមាន១៦៤ភាសាត្រូវបាននិយាយដោយជនជាតិដើមភាគតិចនិងជនជាតិភាគតិចនៅក្នុងតំបន់ទន្លេមេគង្គហើយនឹងបាត់បង់ក្នុងកំលុងសតវត្សរ៍ទី២១។ការគណនាការបាត់បង់គឺ១ឬ២ភាសាជារៀងរាល់ឆ្នាំក្នុងប្រទេសទាំង៥តាមបណ្តោយទន្លេមេគង្គ។ភាសាបានបន្តបាត់បង់និងវិវឌ្ឍតាមរយៈប្រវត្តិសាស្រ្តមនុស្សជាតិប៉ុន្តែ អត្រានៃការរលត់សាបសូន្យបានកើនឡើងយ៉ាងខ្លាំងក្នុងរយៈពេលជាង៥០០ឆ្នាំកន្លងហើយនេះជាការគួរបារម្ភ (Nettleនិង Romaine ២០០០)។

## តើអ្វីជាការគំរាមកំហែងដល់ភាសាភាគតិច?

កត្តាគំរាមកំហែងដល់ភាសាភាគតិចដ៏ធំបំផុតក្នុងតំបន់ទន្លេមេគង្គគឺកើនឡើងយ៉ាងឆាប់រហ័សនៃភាសាធំៗដូចជាភាសាជាតិនិងភាសាផ្លូវការនានា។ពិសេសការអប់រំសាធារណៈលើកទឹកចិត្តឬសូម្បីតែតម្រូវប្រើប្រាស់និងទទួលយកភាសាធំៗ។ខណៈកុមារនៃក្រុមជនជាតិភាគតិចត្រូវការរៀនភាសាជាតិនិងភាសាផ្លូវការហើយពួកគេមានសិទ្ធិធ្វើដូច្នោះវាជាបញ្ហាដែលគ្រូបង្រៀននិងឪពុកម្តាយត្រូវបើកចំហរឬបើកចំហរដោយព្យាយាមរាំងខ្ទប់ឲ្យប្រើប្រាស់ភាសាភាគតិចទាំងនោះ។នេះនាំឲ្យកុមារមានសំណួរអំពីតម្លៃនៃដើមកំណើតនិងការអប់រំ



ស្ត្រីជនជាតិខមុក្នុងស្រុកប៉ាក់បេង, ខេត្តឧត្តមសៃ នៅភាគខាងត្បូងប្រទេសឡាវ

របស់ពួកគេ។ជាលទ្ធផលភាសាភាគតិចមិនត្រូវបានយកមកប្រើនៅក្នុងសាលារៀនហើយសូម្បីតែនៅតាមផ្ទះដូច្នេះភាសាមិនត្រូវបាន

[3]Nettle (1999) រាយការណ៍ថា ភាគរយនៃភាសាទាំងអស់ មានអ្នកនិយាយតិចជាង១០,០០០នាក់ ត្រូវជា៩២.៨% ក្នុងតំបន់អូស្រ្តាលី /អូសេអានី ៧៦.៥%ក្នុងអាមេរិកខាងត្បូង ៧៧.៨%ក្នុងអាមេរិកខាងជើង ៣៦.៤%ក្នុងអាមេរិកកណ្តាល ៣២.៦%ក្នុងអាហ្វ្រិក និង ៣០.២%ក្នុងអឺរ៉ុប ។ ទូទាំងសាកលជាមធ្យមគឺ ៥៩.៤% និងជាមធ្យមក្នុងអាស៊ីគឺ៥២.៨% ។

ចែកចាយដល់មនុស្សជំនាន់ក្រោយ។លើសពីនោះទៀតភាសាធំៗបានពង្រីកនិងមានឥទ្ធិពលតាមរយៈទូរទស្សន៍វិទ្យុកាសែតនិងប្រព័ន្ធផ្សព្វផ្សាយផ្សេងៗក៏ដូចជាវប្បធម៌ប្រជាប្រិយក្នុងខ្សែភាពយន្តនិងចំរៀង។ បន្ថែមជាងនេះទៀតភាសាអង់គ្លេសដើរតួរជាភាសា«អន្តរជាតិ»សំរាប់ការទំនាក់ទំនងក្នុងតំបន់ទន្លេមេគង្គជាមួយការបញ្ចូលប្រទេសអាស៊ានដែលនឹងមកដល់ក្នុងឆ្នាំ២០១៥ជាការជំរុញឱកាសបាត់បង់ការឲ្យតម្លៃភាសាភាគតិចថែមទៀត។

ជម្លោះនិងសង្គ្រាមស៊ីវិលគ្រោះធម្មជាតិរោគរាតត្បាតនិង (ការបង្ខំ)ផ្លាស់ប្តូរទីលំនៅដោយសារគំរោងអភិវឌ្ឍធំៗដូចជាការសាងសង់ទំនប់គឺជាការគំរាមកំហែងដល់ភាពរស់រានរបស់ភាសាភាគតិចផងដែរ។អ្នកនិយាយភាសាមងជាជនជាតិដើមភាគតិចរស់នៅក្នុងភាគខាងត្បូងប្រទេសភូមានិងថៃបានរងគ្រោះរញ្ជួយផែនដីនិងស៊ូណាមិយ៉ាងខ្លាំងក្នុងខែធ្នូឆ្នាំ២០០៤។ពីមុននោះពួកគេមានស្ថានភាពសេដ្ឋកិច្ចនិងសង្គមអន់ថយរួចទៅហើយប៉ុន្តែអ្នកនិយាយភាសាមងជាពិសេសអ្នករស់នៅតាមឆ្នេរសមុទ្រពួកគេបានបាត់បង់ទូកនិងផ្ទះទៅតាមស៊ូណាមិដែលគឺជាការប្រឈមជាមួយវិបត្តិ (Skehan២០១២) ។ភូមិដែលមានអ្នកនិយាយភាសាអ៊ូគុងជាភាសាមានដើមកំណើតពីភាសាស៊ីណូ-ទីបេរស់នៅក្នុងតំបន់ខាងលិចប្រទេសថៃត្រូវបានអាជ្ញាធរ អគ្គិសនីថៃបង្ខំឲ្យរើលំនៅឋានដើម្បីសាងសង់ទំនប់។ជាលទ្ធផលការរួបរួមនៅក្នុងសហគមន៍មានភាពទន់ខ្សោយបង្កើនជាឧបសគ្គក្នុងការថែរក្សាភាសានិងអត្តសញ្ញាណថែមទៀត (Bradley១៩៨៩)។



ស្ត្រីជនជាតិយ៉ាហឿនតាមតំបន់តន្លេសេកុង ភាគខាងត្បូងប្រទេសឡាវ

ភាសារបស់ជនជាតិដើមភាគតិចនិងជនជាតិភាគតិចបានបំពេញគតិបណ្ឌិតនិងចំណេះដឹងប្រមូលផ្តុំតាមរយៈរបៀបរស់នៅជាប្រពៃណីនិងការរស់នៅបែបធម្មជាតិ។មានអ្នកស្រាវជ្រាវខ្លះបាននិយាយថាមនុស្សកើតមកជាមួយភាសានិងវប្បធម៌( McCarty, Skutnabb-KangasនិងMagga២០០៧) ។

**ឯកសារយោង:**

Bradley, David. 1989. The Disappearance of the Ugong in Thailand. In Nancy Dorian (ed.) *Investigating Obsolescence: Studies in Language Contraction and Death.* Cambridge, UK: Cambridge University Press 33-40.

Crystal, David. 2000. *Language Death.* Cambridge, UK: Cambridge University Press.

Lewis, M. Paul (ed.) 2009. *Ethnologue: Languages of the World, 16th Edition.* Dallas, Texas: SIL International.

http://www.ethnologue.com/

McCarty, Teresa L., Tove Skutnabb-Kangas, and Ole Henrik Magga. 2007. Education for Speakers of Endangered Languages. In *Handbook of Educational Linguistics*.Oxford, UK: Oxford University Press 297-311.

Nettle, Daniel. 1999. *Linguistic Diversity*. Oxford, UK: Oxford University Press.

Nettle, Daniel, and Suzanne Romaine. 2000. *Vanishing Voices: The Extinction of the World's Languages.* Oxford: UK, Oxford University Press.

Skehan, Craig. 2012. Time Running out for Moken Way of Life. *Bangkok Post* May 13, 2012. http://www.bangkokpost.com/news/investigation/293059/time-running-out-for-moken-way-of-life

ឱយទុហ្យិយូគិ

# ៦. ការបាត់បង់ព្រៃឈើនៅក្នុងបណ្តាប្រទេសតាមបណ្តោយទន្លេមេគង្គ

## ១. ការពឹងអាស្រ័យព្រៃឈើរបស់ប្រជាជន

«ព្រៃឈើគឺជាផ្ទះរបស់ខ្ញុំ ។ ខ្ញុំមិនអាចរស់នៅដោយគ្មានផ្ទះរបស់ខ្ញុំបានទេ» ។ ពាក្យនេះបាននិយាយដោយកសិករម្នាក់ ដែលកំពុងរស់តាមភ្នំក្នុងប្រទេសឡាវ ។ ជីវិតរស់នៅតាមស្រុកជនបទ ក្នុងបណ្តាប្រទេសតាមបណ្តោយទន្លេមេគង្គ សូម្បីតែបច្ចុប្បន្ននេះក៏ដោយ ក៏នៅពឹងផ្អែកធនធានធម្មជាតិ ព្រៃឈើ និងទន្លេ[1]។

នៅក្នុងមហាអនុតំបន់ទន្លេមេគង្គ(GMS)មានប្រាំប្រទេស៖ ឡាវ ភូមា ថៃ កម្ពុជា និង វៀតណាម រួមជាមួយខេត្តពីររបស់ចិន ៖ តំបន់ស្វយភាព យូណាន និង គាងស៊ីហ្ស៊ូអាង ដែលមានប្រជាជនប្រមាណ៧០លាននាក់ រស់នៅពឹងអាស្រ័យលើប្រពន្ធ័អេកូឡូស៊ី សំរាប់ប្រកបរបរចិញ្ចឹមជីវិត ទឹក អាហារ និង សេវាកម្មសំខាន់ៗ ទាក់ទងនឹងការរស់រាន (WWF 2013:5)។

ប្រជាជនភ្ជាប់របរកសិកម្ម អាស្រ័យលើបរិស្ថានធម្មជាតិ បង្គ្រប់ផលិតផលអាហារបរិភោគរបស់ពួកគេមានការលំបាកថែរក្សា ហើយវាបានថយចុះ ផលិតផលព្រៃឈើ រួមមាន ទំពាំង ផ្សិត និង សត្វព្រៃ ដែលមាននៅក្នុងព្រៃ[2]។ ឈើដែលពួកគេប្រើសំរាប់សង់លំនៅឋាន និងស្លឹកប្រើសំរាប់ប្រក់ដំបូលផ្ទះរបស់ពួកគេ ក៏មាននៅក្នុងព្រៃ ។ ជាបន្ថែមទៀត ពួកគេមានមរតកចំណេះដឹងក្នុងការប្រើប្រាស់ឱសថរុក្ខជាតិ ដើម្បីព្យាបាលជម្ងឺផ្សេងៗ ។

លើសពីនោះ ទម្លាប់គោរពអ្នកតាព្រៃរបស់សាសនាផ្សេងៗ រួមមាន ក្នុងខេត្តយូណានប្រទេសចិន ឡាវ ភាគឥសានថៃ និង ភាគពាយព្យវៀតណាម ហើយរបស់ពិសិដ្ឋផ្សេងៗទៀតត្រូវបានថែទាំ មិនឲ្យប៉ះពាល់ កាប់ឈើ ឬ ប្រើប្រាស់ធនធានព្រៃឈើទាំងនោះច្រើនហួសហេតុ[3]។

ក្រុមកុលសម្ព័នជនជាតិដើមភាគតិច អនុវត្តការកាប់ឆ្ការវិលជុំ នៅក្នុងតំបន់ភ្នំនៃបណ្តាប្រទេសតាមដងទន្លេមេគង្គ ។ ពួកគេកាប់ឆ្ការ ដាំ និងដុតរានដីដាំបណ្តុះគ្រាប់ពូជនៅលើដីរានសំរាប់រយៈពេលខ្លីបន្ទាប់មក

---

[1]អង្គការMekong Watch បានប្រមូលព័ត៌មានផលិតជាវីដេអូឯកសារ ឆ្នាំ២០០៣ មានចំណងជើង «អន្តរកាល ការផ្លាស់ប្តូរព្រៃឈើ និងរបៀបរស់នៅ ក្នុងប្រទេសឡាវ» (http://www.youtube.com/watch?v=ac9OIxLWm2I) ។ វីដេអូនេះណែនាំអំពីទំនាក់ទំនងរវាងព្រៃឈើ និង ជីវភាពរស់នៅ និង វប្បធម៌របស់ជនជាតិឡាវ ព្រមទាំងការប៉ះពាល់ផ្សេងៗ លើជីវះចំរុះនៃប្រពន្ធ័អេកូឡូស៊ី និងរបៀបរស់នៅអាស្រ័យព្រៃឈើ មកពីគោលនយោបាយ និង សកម្មភាពសេដ្ឋកិច្ច ដែលមានគោលបំណងអភិវឌ្ឍសេដ្ឋកិច្ចក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ។

[2]សំរាប់លំអិតបន្ថែម សូមមើលឯកសារសង្ខេបទំព័រX «សុវត្ថិភាពអាហារ និង ការប្រើប្រាស់ផលិតផលមិនមែនព្រៃឈើ នៅក្នុងប្រទេសតាមបណ្តោយទន្លេមេគង្គ ~ករណីរបស់ប្រទេសឡាវ»

[3]សូមមើលទំព័រX«ជំនឿអរូបិយ និង កិច្ចបង្ការព្រៃឈើ នៅក្នុងបណ្តាប្រទេសតាមបណ្តោយទន្លេមេគង្គ»

បោះបង់ដីបន្ទាប់ពីប្រមូលផល ដើម្បីទុកឲ្យរុក្ខជាតិដុះឡើងវិញ ក្នុងកំឡុងពេលបន្ទាប់ ក្រោយមកពួកគេធ្វើដូច្នេះម្តងទៀត សំរាប់បណ្តុះគ្រាប់ពូជ ។ ប្រជាជនធ្វើកសិកម្មវិលជុំម្តងហើយម្តងទៀត នៅលើដីចម្ការ និង ព្រៃឈើដដែល ។ នៅក្នុងព្រៃទីពីរនៃចម្ការវិលជុំ ពួកគេអាចប្រមូលផលិតផលព្រៃឈើផ្សេងៗទៀត ។ ផលិតផលព្រៃឈើទាំងនេះ ខ្លះគ្មានដុះនៅកន្លែងផ្សេងទេ ប៉ុន្តែវាដុះនៅក្នុងព្រៃទីពីរ ដូច្នេះមនុស្ស និង ព្រៃឈើរស់នៅជាមួយគ្នា ផ្តល់ការគាំពារគ្នាទៅវិញទៅមក ដែលព្រៃឈើផ្តល់មុខរបរចិញ្ចឹមជីវិតដល់មនុស្ស ហើយមនុស្សធានាការពារជីវៈចំរុះ[4]។

ដូចដែលបានដកស្រង់សំដីកសិករជនជាតិឡាវ ដែលបាននិយាយនៅឃ្លាចាប់ផ្តើម ក្នុងរបាយការណ៍នេះ ថា ប្រជាជនដែលរស់នៅក្នុងតំបន់កសិកម្ម តាមបណ្តោយទន្លេមេគង្គ មិនអាចរស់ដោយគ្មានព្រៃឈើទេ ។ ព្រៃឈើក្នុងតំបន់នេះ មានការថយចុះ និង មានការបំផ្លាញយ៉ាងគំហុក ក្នុងកំឡុងកន្លះកណ្តាលសតវត្សកន្លងនាំឲ្យមានការគំរាមកំហែងដល់ការរស់រានរបស់ប្រជាជន ។

## ២.ព្រៃឈើបាត់បង់នៅតាមបណ្តោយទន្លេមេគង្គ*

យោងតាមស្ថិតិដែលប្រមូលក្នុងឆ្នាំ២០១០ ដោយអង្គការស្បៀងអាហារ និង កសិកម្មសហប្រជាជាតិ (FAO)ថា បច្ចុប្បន្នមានព្រៃឈើចំនួន៩០លានហត កំពុងសេសសល់ក្នុងប្រទេសទាំង៥ គឺមាន ១៣%នៃចំនួនព្រៃបឋម ១០%ជាចម្ការឈើដាំ និង សល់ពីការបំផ្លាញ តែវាជាព្រៃធម្មជាតិ ដែលនឹងបន្តដុះលូតលាស់តាមធម្មជាតិ ប្រសិនបើទុកវាឲ្យនៅសេសសល់ (តួលេខ១) ។អត្រាព្រៃឈើគ្របដណ្តប់ក្នុងប្រទេសនីមួយៗគឺ កម្ពុជា ៥៧% ឡាវ៦៨% ភូមា៤៨% ថៃ៣៧% និង វៀតណាម៤៤% ។

បើបំបែកជាប្រភេទព្រៃផ្សេងៗ ប្រទេសកម្ពុជា និង វៀតណាម មានព្រៃឈើបឋមសេសសល់តិចតួចបំផុត (៣២២,០០០ហតក្នុងប្រទេសកម្ពុជា ៨០,០០០ហតក្នុងប្រទេសវៀតណាម) បើប្រៀបធៀបជាមួយប្រទេសដ៏ទៃទៀត ថៃ និង វៀតណាម មានតំបន់ធំៗគ្របដណ្តប់ដោយចម្ការឈើដាំ ។

[4]សូមមើលឯកសារទំព័រIX«ចម្ការវិលជុំ និង ជីវិតរស់នៅតាមតំបន់ភ្នំ ~ករណីរបស់ប្រទេសឡាវ»




តួលេខ១. តំបន់ព្រៃឈើ និងព្រៃឈើគ្រប់ដណ្តប់ក្នុងបណ្តាប្រទេស GMS

យោងតាម FAO (2010).[5]

